# សេចក្តីថ្លែងរបស់បេក្ខជន

## ព្រឹទ្ធសភាសហរដ្ឋអាមេរិក

- បំរើជាព្រឹទ្ធសភាម្នាក់ នៃព្រឹទ្ធសភាពីរនាក់ ដែលតំណាងឲ្យផលប្រយោជន៍របស់រដ្ឋកាលីហ្វ័រនីញ៉ា នៅក្នុងសភាសហរដ្ឋអាមេរិក។
- ស្នើ និងបោះឆ្នោតលើច្បាប់ជាតិថ្មី។
- បោះឆ្នោតលើការបញ្ជាក់ចៅក្រមរដ្ឋបាលសហព័ន្ធ ចៅក្រមតុលាការកំពូលសហរដ្ឋអាមេរិក និងការតែងតាំងពីប្រធានាធិបតីថ្នាក់ខ្ពស់ជាច្រើន ចំពោះមុខតំណែងស៊ីវិល និងយោធា។

---

### **Pamela Elizondo** | បៃតង



*http://www.facebook.com/Pamela.Elizondo.USSENATE*


P.O. Box 104
Laytonville, CA 95454

ទូរស័ព្ទ: (707) 354-1498
អ៊ីមែល: pamelizondo2004@yahoo.com
http://www.facebook.com/Pamela.Elizondo.USSENATE


---

### **Akinyemi Olabode Agbede** | ប្រជាធិបតេយ្យ



សង្គ្រោះអាមេរិក! សង្គ្រោះអាមេរិក!! សង្គ្រោះអាមេរិក!!! ពលរដ្ឋកាលីហ្វ័រនីញ៉ា! ចូរយើងសង្គ្រោះអាមេរិកទាំងអស់គ្នា ពីការប្រែក្លាយទៅជាប្រទេសក្រខ្សត់។ ល្មមគឺល្មមហើយ ពីព្រោះប្រជាជនអាមេរិកកំពុងវេទនាណាស់។ ពួកអ្នកនៅក្នុងវ៉ាស៊ីងតោន បានធ្វើឲ្យប្រទេសនេះអន់ខ្សោយ។ ដោយសារហេតុនេះ ការបោះឆ្នោតឲ្យបណ្ឌិត Akinyemi Agbede ធ្វើជាព្រឹទ្ធសភាសហរដ្ឋអាមេរិកជាបន្ទាប់ទៀត តំណាងឲ្យសុវណ្ណរដ្ឋកាលីហ្វ័រនីញ៉ានៅឆ្នាំ 2016 គឺជាចំឡើយ ប្រយោជន៍ឲ្យមាតុភូមិរបស់យើងបានសំបូររុងរឿងឡើងវិញ។


6775 Santa Monica Blvd.
Suite 4-254
Los Angeles, CA 90038

ទូរស័ព្ទ: (559) 250-2563
អ៊ីមែល: yemibode@hotmail.com
www.americamustregainitsgreatness2016.com


---

លំដាប់លំដោយនៃសេចក្តីថ្លែង ត្រូវបានសំរេចដោយការចាប់យកអក្ខរក្រមព្រាវៗ។ សេចក្តីថ្លែងនៅទំព័រនេះ បានឧបត្ថម្ភដោយបេក្ខជន និងមិនទាន់បានពិនិត្យមើលភាពត្រឹមត្រូវនៅឡើយទេ។ សេចក្តីថ្លែងនិមួយៗ ត្រូវបានបញ្ជូនមកដោយស្ម័គ្រចិត្ត និងបានបង់ប្រាក់ដោយបេក្ខជន។ បេក្ខជនដែលមិនបានបញ្ជូនសេចក្តីថ្លែងមក បើមិនដូច្នេះទេ អាចនឹងមានគុណសម្បត្តិ បង្ហាញនៅលើសន្លឹកឆ្នោត។

### Jerry J. Laws | សាធារណរដ្ឋ

រូបថតមិនបាន
បញ្ជូនមកទេ

អ្នកប្រកាន់រដ្ឋធម្មនុញ្ញ។ អាមេរិកាំងនិយម។ *www.lawsussenate2016.com*


14411 Northstar Ave.
Victorville, CA 92392

ទូរស័ព្ទ: (760) 952-0294 (ផ្ទះ) (760) 220-9814 (ទូរស័ព្ទដៃ)
អ៊ីមែល: jerryjosephlaws2016@aol.com
www.lawsussenate2016.com


### Loretta L. Sanchez | ប្រជាធិបតេយ្យ



រដ្ឋកាលីហ្វ័រនីញ៉ា ត្រូវការអ្នកមានបទពិសោធន៍ និងជាអ្នកដឹកនាំមានថ្វីដៃ ដើម្បីដោះស្រាយបញ្ហាសេដ្ឋកិច្ចច្រើនសន្ធឹក ការអប់រំ និងឧបសគ្គសន្តិសុខ ដែលយើងរាល់គ្នាប្រឈមមុខសព្វថ្ងៃនេះ។ ព្រឹទ្ធសភាសហរដ្ឋអាមេរិករបស់យើងជាបន្ទាប់ទៀត ត្រូវតែមានបទពិសោធន៍ជ្រៅជ្រះខាងនីតិបញ្ញត្តិ និងសន្តិសុខជាតិ ទាំងចែកចាយបទពិសោធន៍ជីវិតនៃមនុស្សដែលធ្វើការ។ ខ្ញុំមានបទពិសោធន៍ និងហេតុនេះហើយរូបខ្ញុំនេះគឺជាបេក្ខជនដ៏ល្អបំផុតសំរាប់ការងារ។ ខ្ញុំមកពីក្រុមគ្រួសារសហជីព នៃមាតាបិតាអន្តោប្រវេសន៍ ដែលបានពុះពារដើម្បីផ្តល់អ្វីសំរាប់កូនរបស់គាត់ប្រាំពីរនាក់។ ខ្ញុំបានខំធ្វើការតាមរយៈមហាវិទ្យាល័យ ដោយមានជំនួយប្រាក់ឧបត្ថម្ភពីរដ្ឋាភិបាល និងសហជីព និង Anaheim Rotary Club បានបង់ថ្លៃសំរាប់ MBA (បរិញ្ញាទោសិល្បៈពាណិជ្ជកម្ម) របស់ខ្ញុំ។ ខ្ញុំដឹងពីការពុះពារនៃគ្រួសារដែលធ្វើការ។ មាតាបិតារបស់ខ្ញុំបានធ្វើការទាំងលំបាកលំបិន បានឲ្យតម្លៃការអប់រំ និងជាមាតាបិតាមួយប៉ុណ្ណោះនៅក្នុងប្រវត្តិសាស្ត្រអាមេរិក ដែលបានបញ្ជូនកូនស្រីពីរនាក់ទៅសភា។ ហេតុនោះហើយ ខ្ញុំបានតស៊ូដោយរំជើបរំជួលចិត្តនៅក្នុងសភា សំរាប់ការអប់រំចំនួន 20 ឆ្នាំ, ជំនួយថ្លៃសាលា, កែទំរង់សុខាភិបាល, កែទំរង់អន្តោប្រវេសន៍, សមភេទ, សិទ្ធិ LGBT, សិទ្ធិរបស់កម្មករ, ការការពារបរិស្ថាន។ ខ្ញុំក៏បានបង្ហាញពីការវិនិច្ឆ័យដោយឯករាជ្យ និងអង់អាចផងដែរ នៅពេលណាវាសំខាន់បំផុត: ខ្ញុំបានបោះឆ្នោតប្រឆាំងសង្គ្រាមអ៊ីរ៉ាក, ក្រិត្យអ្នកស្នេហាជាតិ, និងធនាគារសង្គ្រោះនៅពេលអ្នកឯទៀតតិចតួចបានធ្វើ។ ឋានៈជាសមាជិកព្រឹទ្ធសភាជើងចាស់ម្នាក់ នៃគណៈកម្មាធិការសេវាអាវុធ និងសន្តិសុខមាតុភូមិ ខ្ញុំបានធ្វើការដើម្បីឲ្យប្រាកដថាកងទ័ពរបស់យើងបានហ្វឹកហ្វឺន និងបានប្រដាប់ខ្លួនដើម្បីឲ្យបានឈ្នះ និងត្រូវបានថែរក្សា នៅពេលគេមកផ្ទះវិញ។ ខ្ញុំគឺជាបេក្ខជនតែម្នាក់ប៉ុណ្ណោះ ដែលមានបទពិសោធន៍ជាចាំបាច់ខាងសន្តិសុខជាតិ ដើម្បីរក្សាប្រទេសអាមេរិកឲ្យបានសុខ។ ឋានៈជាព្រឹទ្ធសភារបស់លោកអ្នក ខ្ញុំនឹងតតាំងសំរាប់ពលរដ្ឋកាលីហ្វ័រនីញ៉ាទាំងអស់ ដូច្នេះហើយ យើងទាំងអស់គ្នាអាចមានអនាគតដ៏រឹងមាំ និងថ្កើងថ្កាន។ ខ្ញុំសូមបន្ទាបខ្លួនសុំសំឡេងឆ្នោតរបស់លោកអ្នក។


P.O. Box 6037
Santa Ana, CA 92706

ទូរស័ព្ទ: (714) 774-0236
អ៊ីមែល: info@loretta.org
http://loretta.org


លំដាប់លំដោយនៃសេចក្តីថ្លែង ត្រូវបានសំរេចដោយការចាប់យកអក្ខរក្រមព្រាវៗ។ សេចក្តីថ្លែងនៅទំព័រនេះ បានឧបត្ថម្ភ ដោយបេក្ខជន និងមិនទាន់បានពិនិត្យមើលភាពត្រឹមត្រូវនៅឡើយទេ។
សេចក្តីថ្លែងនិមួយៗ ត្រូវបានបញ្ជូនមកដោយ ស្ម័គ្រចិត្ត និងបានបង់ប្រាក់ដោយបេក្ខជន។ បេក្ខជនដែលមិនបានបញ្ជូនសេចក្តីថ្លែងមក បើមិនដូច្នេះទេ អាចនឹងមាន គុណសម្បត្តិ បង្ហាញនៅលើសន្លឹកឆ្នោត។

# សេចក្ដីថ្លែងរបស់បេក្ខជន

## ព្រឹទ្ធសភាសហរដ្ឋអាមេរិក

### Duf Sundheim | សាធារណរដ្ឋ



ការប្រែប្រួលសេដ្ឋកិច្ច និងការវាយប្រហារដោយភេរវជន បានបង្កើតនូវសម័យព្រួយបារម្ភ។ យើងចង់បាន*ការប្រព្រឹត្តិ* ពីអ្នកដឹកនាំរបស់យើង; ផ្ទុយទៅវិញ យើងបានការប្រកាន់បក្សពួក និងបែកបាក់គ្នាហួសហេតុ ជារដ្ឋាភិបាលឥតប្រសិទ្ធិភាព។ ខ្ញុំសន្យាថាត្រូវ*ខុសប្លែក*។ ខ្ញុំនឹងមានសេចក្ដីក្លាហាន *មានតុល្យភាព*។ ខ្ញុំនឹងរកដំណោះស្រាយដែលអាចសំរេចបំណង។ រដ្ឋកាលីហ្វ័រនីញ៉ាកាលពីមុនគឺជា “ទឹកដីសុបិន”; ដែលបណ្ដាលចិត្តដើម្បីប្រជែង ដើម្បីសំរេចបំណង—និងដើម្បីឈ្នះ សំរាប់ខ្លួនរបស់យើង និងគ្រួសាររបស់យើង។ ប៉ុន្តែសុបិននោះកំពុងតែបានថប់ដង្ហើមដោយសារអ្នកដឹកនាំ ដែលបានយកគោលជំហរ*ហួសហេតុ*។ លទ្ធផលគឺពាណិជ្ជកម្ម អ្នកជិតខាងរបស់យើង និងកូនៗរបស់យើង កំពុងតែចាកចេញពីរដ្ឋកាលីហ្វ័រនីញ៉ា។ សាលារៀនរបស់យើងមានចំណាត់ថ្នាក់ទី 41 នៅក្នុងប្រទេស។ ពន្ធកាន់តែឡើងថ្លៃ និងតម្លៃ នៃការរស់នៅក៏កាន់តែខ្ពស់កប់ពពក។ ការហូរឈាមនេះត្រូវតែបញ្ឈប់ ។ ខ្ញុំមានបទពិសោធន៍ និងទឹកចិត្តដើម្បីជួសជុលការនេះ។ ខ្ញុំបាន ទទួលសញ្ញាប័ត្រពីសាលាច្បាប់ Stanford និង Northwestern។ *ខ្ញុំដោះស្រាយបញ្ហានានាសំរាប់ការរស់នៅ។* តុលាការរដ្ឋបាល សហព័ន្ធ បានយល់ព្រមខ្ញុំថាជាអ្នកសំរុះសំរួល និងជាចៅក្រមស្ម័គ្រចិត្តនៃការសំរុះសំរួល។ ខ្ញុំធ្លាប់បានធ្វើជាប្រធាននៃគណៈបក្សសាធា រណរដ្ឋ កាលីហ្វ័រនីញ៉ា មើលខុសត្រូវការកោះហៅអភិបាលរដ្ឋវិញដោយជោគជ័យ និងបានជាប់ឆ្នោតសាថ្មីជាដំបូងបំផុត; ពីព្រោះ*យើងបានធ្វើអ្វីៗ*។ អ្នកដឹកនាំមកពីគ្រប់ផ្នែកដែលអាចស្រមៃបាន កំពុងគាំទ្រទស្សនៈរបស់ខ្ញុំ ដើម្បីស្ដាបនា “សុបិនកាលីហ្វ័រនីញ៉ា” ឡើងវិញ។ អតីតៈរដ្ឋលេខាធិការ George Shultz, មេដឹកនាំភាគច្រើន Kevin McCarthy, John Chambers របស់ Cisco, ចៅហ្វាយក្រុងហ្វ្រេស្ន Ashley Swearengin, សមាគមពាណិជ្ជកម្មតូចកាលីហ្វ័រនីញ៉ា។ ខ្ញុំត្រូវបាននាំផ្លូវដោយរដ្ឋធម្មនុញ្ញ។ ការងារដ៏ចំបងរបស់ខ្ញុំគឺសន្តិសុខជាតិ ការអប់រំ និងទឹក។ សូមមើល *SundheimforSenate.com* សំរាប់សេចក្ដីពិស្ដារនៃនយោបាយ។ បូរណភាព។ សុភវិនិច្ឆ័យ។ លទ្ធផល។ វាគឺជាគ្រិះស្ថានរបស់ខ្ញុំ—និងជាគ្រិះស្ថាននៅពេលយើងនឹងយកបាន “ទឹកដីសុបិន” របស់យើងមកវិញ។

27319 Julietta Lane
Los Altos Hills, CA 94022

ទូរស័ព្ទ: (650) 209-0949
អ៊ីមែល: dufsundheim37@gmail.com
SundheimforSenate.com

### Ling Ling Shi | គ្មានប្រកាន់គណៈបក្ស

រូបថតមិនបាន
បញ្ជូនមកទេ

ឈរឈ្មោះសំរាប់បេះដូងរបស់ព្រះ និងសេរីភាពរបស់ប្រជាជនអាមេរិក ប្រឆាំងមហារីកវរ 10 យ៉ាងខាងសេដ្ឋកិច្ច និងផ្នែកជាប់ទាក់ទងខាងសេដ្ឋកិច្ច។

P.O. Box 55
Rancho Cucamonga, CA 91729

ទូរស័ព្ទ: (909) 728-0578
អ៊ីមែល: lingling_lilyofvalley_shi@yahoo.com
www.wellsARK.com

លំដាប់លំដោយនៃសេចក្ដីថ្លែង ត្រូវបានសំរេចដោយការចាប់យកអក្ខរក្រមព្រាវៗ។ សេចក្ដីថ្លែងនៅទំព័រនេះ បានឧបត្ថម្ភដោយបេក្ខជន និងមិនទាន់បានពិនិត្យមើលភាពត្រឹមត្រូវនៅឡើយទេ។ សេចក្ដីថ្លែងនិមួយៗ ត្រូវបានបញ្ជូនមកដោយស្ម័គ្រចិត្ត និងបានបង់ប្រាក់ដោយបេក្ខជន។ បេក្ខជនដែលមិនបានបញ្ជូនសេចក្ដីថ្លែងមក បើមិនដូច្នេះទេ អាចនឹងមានគុណសម្បត្តិ បង្ហាញនៅលើសន្លឹកឆ្នោត។

# សេចក្តីថ្លែងរបស់បេក្ខជន

## ព្រឹទ្ធសភាសហរដ្ឋអាមេរិក

### Paul Merritt | គ្មានប្រកាន់គណៈបក្ស



កាលីហ្វ័រនីញ៉ា មានឈ្មោះក្នុងប្រវត្តិសាស្ត្រ . . . សូមបោះឆ្នោតឲ្យព្រឹទ្ធសភាឯករាជ្យ Merritt។ បោះឆ្នោតឲ្យអ្នកគិតដោយឯករាជ្យ។ បោះឆ្នោតឲ្យមនុស្សមិនមែនគណៈបក្សកំពុងកាន់អំណាច។ រដ្ឋាភិបាលជាតិរបស់យើងគឺដើរអួសជើង។ យើងត្រូវការអ្នកការពារសហរដ្ឋអាមេរិកដ៏រឹងប៉ឹង។ Merritt មានចំណេះដឹងរឹងមាំទៅលើរឿងរ៉ាវអន្តរជាតិ។ ខ្ញុំជឿក្នុងជំនឿដែលគោរពប្រជាជន និងសាសនាទាំងអស់។ Merritt គាំទ្របេងព្រំដែនសន្តិសុខរបស់ព្រឹទ្ធសភា Feinstein, គ្មានការខួងយកប្រេងក្នុងសមុទ្រ និងក្រិត្យការពារបរិស្ថានរហោឋានរបស់យើង។ Merritt ប្រកាន់ខ្ជាប់គំនិតរបស់លោកប្រធានាធិបតី Reagan ថារដ្ឋាភិបាលតូចគឺល្អបំផុត។ សាវតារៈ វិជ្ជាច្បាប់ពីរ, ជើងសារជំនួញ, ម្ចាស់សណ្ឋាគារ, បានជាប់ឆ្នោតជាក្រុមប្រឹក្សាក្រុង។ គណៈម្ចាស់ផ្ទះនៅ: Palm Springs, Santa Barbara, San Francisco, ខោនធី Orange។ សមាជិកអ្នកអភិរក្សជីវិតធម្មជាតិ។ ភាគច្រើននៃមហាសេដ្ឋីបក្សសាធារណរដ្ឋ និងចៅហ្វាយសហជីពបក្សប្រជាធិបតេយ្យ មិនតំណាងឲ្យលោកអ្នកឡើយ! Merritt គឺឯករាជ្យសំរាប់ពលរដ្ឋទាំងអស់។ Paul Merritt គឺជាពលរដ្ឋកាលីហ្វ័រនីញ៉ា!

P.O. Box 9145
Laguna, CA 92652

ទូរស័ព្ទ: (949) 249-2492
អ៊ីមែល: electmerrittsenator@yahoo.com
merrittforsenate.info

### Massie Munroe | ប្រជាធិបតេយ្យ



បេក្ខភាពរបស់ខ្ញុំតំណាងឲ្យរដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិក ជាកិច្ចសន្យារវាងប្រជាជនអាមេរិក និងរបស់រដ្ឋាភិបាលអាមេរិកតែប៉ុណ្ណោះ "នៃប្រជាជន ដោយប្រជាជន សំរាប់ប្រជាជន" ដើម្បីឲ្យបានស្តាបនាឡើងវិញ និងបានពង្រឹងនៅប្រទេសអាមេរិក និងលាងសន្ទឹងទៅអង្គការសហប្រជាជាតិ ជាកិច្ចសន្យារវាងប្រជាជនទាំងអស់ នៃពិភពលោករបស់យើង តាមរយៈការដឹកនាំអាមេរិក និងការទូត។ ធនាគារិកអន្តរជាតិ, អ្នកដឹកនាំសហគ្រាសពហុជាតិ, យោធា និងប៉ូលីស ទាំងអស់ត្រូវតែគោរពច្បាប់ 100% ដោយប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ នៃសហរដ្ឋអាមេរិក/អង្គការសហប្រជាជាតិ នៅក្នុងវិញ្ញាណនៃសេចក្តីពិត បំរើមនុស្សទាំងអស់ក្នុងសន្តិភាព។ ការផ្លាស់ប្តូរពីយុគសម័យឧស្សាហកម្មបច្ចេកវិជ្ជា ទៅ "សម័យបច្ចេកវិជ្ជាថាមពល" ថ្មី *នឹងជ្រួតជ្រាបទីផ្សារការងារសហរដ្ឋអាមេរិក សំរាប់ 500 ឆ្នាំខាងមុខ។*
ការឃោសនារបស់ខ្ញុំ តំណាងឲ្យការបញ្ចប់វិន័យធនាគារិកអន្តជាតិ និងស្ថាប័នហិរញ្ញវត្ថុរបស់គេ ដែលតែប្រយោជន៍របស់ជាតិ;
ការស្តាបនាវិន័យរបស់ប្រជាជន ឡើងវិញ តាមការបង្កើត ធនាគាររបស់ពលរដ្ឋ ដើម្បីបំរើជាធនាគារកណ្តាលអាមេរិក;
បញ្ចប់ចិត្តត្រួតត្រាទាសករ; បញ្ចប់ការពិសោធន៍មនុស្សដែលគ្មានការយល់ព្រម; បញ្ចប់ការអត់ឃ្លាន, ភាពអនាល័យ និងអំពើហិង្សា;
ការពារទឹក, ដី, ខ្យល់, ព្រៃព្រឹក្សា, មហាសាគរ និងសត្វ; អនុវត្តតាមសម្បជញ្ញៈព្រះគ្រិស្ទ និងការប្រតិបត្តិរដ្ឋធម្មនុញ្ញយុត្តិធម៌ នៅក្រោមការដឹកនាំនៃសហរដ្ឋអាមេរិក/អង្គការសហប្រជាជាតិ។ តាម រយៈការស្រាវជ្រាវរបស់ខ្ញុំនៅក្នុងប្រទេស និងអន្តរជាតិ និងជាសកម្មជននយោបាយ ដែលខ្ញុំបានសំគាល់ឃើញ *"ចិត្តត្រួតត្រាទាសករ"* តាមបច្ចេកវិជ្ជាសព្វាវុធថាមពលផ្កាយ រណប និងកម្មវិធីវិស្វកម្មសង្គម ដែលបានបន្តបណ្តុះបណ្តាលចំនួន 50 ឆ្នាំកន្លងមក និងបានសំរួល *"ការបំបាត់ភាពសំងាត់"* របស់គេ។ ជាលទ្ធផល ខ្ញុំបានមកនៅក្រោមទណ្ឌកម្មដ៏ធ្ងន់ធ្ងរ ដែលកំពុងតែជាតតល្លែ។ ខ្ញុំសូមស្នើមកលោកអ្នក ជាអ្នកបោះឆ្នោត ដើម្បីឡើងឲ្យខ្ពស់ផុតពីការចោទប្រកាន់មិនពិតទាំងអស់ ដែលវាយប្រហារលើបុគ្គលិកលក្ខណៈ និងបេះដូងដ៏ល្អរបស់ខ្ញុំ។ សូមមើលភស្តុតាងរបស់ខ្ញុំ និងមើលសេវារបស់ខ្ញុំឡើងវិញ។ ប្រធានាធិបតីភាពរបស់ព្រឹទ្ធសភា Bernie Sanders គឺជាចាំបាច់ សំរាប់នាំអាទិ៍ការនេះចូលទៅភាពពិត។

2167 East Chevy Chase Dr.
Glendale, CA 91206-1732

ទូរស័ព្ទ: (818) 943-0661 (ទូរស័ព្ទដៃ) (818) 245-6993 (ការិយាល័យ)
អ៊ីមែល: massie@massieglobal.com
www.massiemunroe4ussenator.com

លំដាប់លំដោយនៃសេចក្តីថ្លែង ត្រូវបានសំរេចដោយការចាប់យកអក្ខរក្រមព្រាវៗ។ សេចក្តីថ្លែងនៅទំព័រនេះ បានឧបត្ថម្ភ ដោយបេក្ខជន និងមិនទាន់បានពិនិត្យមើលភាពត្រឹមត្រូវនៅឡើយទេ។ សេចក្តីថ្លែងនិមួយៗ ត្រូវបានបញ្ជូនមកដោយ ស្ម័គ្រចិត្ត និងបានបង់ប្រាក់ដោយបេក្ខជន។ បេក្ខជនដែលមិនបានបញ្ជូនសេចក្តីថ្លែងមក បើមិនដូច្នេះទេ អាចនឹងមាន គុណសម្បត្តិ បង្ហាញនៅលើសន្លឹកឆ្នោត។

# សេចក្តីថ្លែងរបស់បេក្ខជន

## ព្រឹទ្ធសភាសហរដ្ឋអាមេរិក

### **Tim Gildersleeve** | គ្មានប្រកាន់គណៈបក្ស



ខ្ញុំជាអ្នកជឿព្រះយេស៊ូវគ្រិស្ទ។ ខ្ញុំឈរសំរាប់អ្នកក្រីក្រ ចាស់ជរា និងជនពិការ រឿងរ៉ាវបរិស្ថាន សហជីព ពាណិជ្ជកម្មតូច និងតំណាងឲ្យពលរដ្ឋសាមញ្ញ។ វ៉ិបសៃត៍របស់ខ្ញុំគឺ: *http://www.alternativevoiceforamerica.org*។


ទូរស័ព្ទ: (408) 915-8713
អ៊ីមែល: timg@alternativevoiceforamerica.org
http://www.alternativevoiceforamerica.org


### **President Cristina Grappo** | ប្រជាធិបតេយ្យ



គុណសម្បត្តិការអប់រំ និងជំនាញរបស់ខ្ញុំ ជាផលផ្លែនៃអាជីវកម្មនេះ ប្រយោជន៍ដើម្បីតំណាងឲ្យរដ្ឋកាលីហ្វ័រនីញ៉ា ឋានៈជាព្រឹទ្ធសភារួបរួមគ្នា។ ខ្ញុំប្រកាន់គោលជំហររបស់គណៈបក្សប្រជាធិបតេយ្យ ជាមួយនឹងរឿងរ៉ាវសំខាន់ៗ សំរាប់ការត្រួតត្រាអាវុធ ការជួញដូរមនុស្ស ធ្វើឲ្យចំណាយលើសចំណូលរបស់ជាតិមានតុល្យភាព និងបណ្តើមគំណិតនយោបាយបរទេស។ ខ្ញុំជាអ្នកនិយមប្រើ Facebook ក្នុងសង្គមព័ត៌មាន! តម្លៃជាស្នូលរបស់ខ្ញុំ បណ្តាលទឹកចិត្តប្រជាជនអាមេរិក!


P.O. Box 1307
Alameda, CA 94501


លំដាប់លំដោយនៃសេចក្តីថ្លែង ត្រូវបានសំរេចដោយការចាប់យកអក្ខរក្រមព្រាវៗ។ សេចក្តីថ្លែងនៅទំព័រនេះ បានឧបត្ថម្ភដោយបេក្ខជន និងមិនទាន់បានពិនិត្យមើលភាពត្រឹមត្រូវនៅឡើយទេ។ សេចក្តីថ្លែងនិមួយៗ ត្រូវបានបញ្ជូនមកដោយស្ម័គ្រចិត្ត និងបានបង់ប្រាក់ដោយបេក្ខជន។ បេក្ខជនដែលមិនបានបញ្ជូនសេចក្តីថ្លែងមក បើមិនដូច្នេះទេ អាចនឹងមានគុណសម្បត្តិ បង្ហាញនៅលើសន្លឹកឆ្នោត។

# សេចក្តីថ្លែងរបស់បេក្ខជន

## ព្រឹទ្ធសភាសហរដ្ឋអាមេរិក

### Don J. Grundmann | គ្មានប្រកាន់គណៈបក្ស

រូបថតមិនបាន បញ្ជូនមកទេ

Fight-the-Power.org

425 E. Merle Ct.
San Leandro, CA 94577

ទូរស័ព្ទ: (510) 895-6789
អ៊ីមែល: stoptheirs@hotmail.com
fight-the-power.org

### Herbert G. Peters | ប្រជាធិបតេយ្យ

រូបថតមិនបាន បញ្ជូនមកទេ

អ្នកប្រជាធិបតេយ្យ Andrew Jackson។ រយៈពេល 70 ឆ្នាំដំបូងរបស់យើង; ប្រទេសរបស់យើងបានលូតលាស់ និងបានចំរុងចំរើន។ យើងមិនដែលមានពន្ធលើប្រាក់ចំណូលទេ។ ពាក្យស្លោកៈ វាសនាជាក់ស្តែង។ ប្រធានាធិបតីប្រជាធិបតេយ្យ; មានប្រាជ្ញាបំផុតៈ លោក Andrew Jackson បានធ្វើឲ្យគំរោងថវិកាមានតុល្យភាពក្នុងពេលប្រាំពីរ នៃប្រាំបីឆ្នាំ។ លោក Franklin Pierce បានប្រើអាជ្ញាបដិសេធន៍គំរោងច្បាប់វើលហ្វ៍រ។ ដើម្បីក្រឡាស់វិលវង់ថយក្រោយក្នុងពេល 118 ឆ្នាំកន្លងទៅៈ ធ្វើឲ្យគំរោងថវិការបស់យើងមានតុល្យភាព, រឹងទទឹងនឹងសង្គ្រាម, កាត់បន្ថយតម្លៃ, កាត់បន្ថយពន្ធ, លុបចោលច្បាប់វើលហ្វែរ និងអប្បរិមាប្រាក់ឈ្នួល ប្រយោជន៍ឲ្យទាំងអស់គ្នាអាចរកការងារបាន។ ព្រះវិហារ និងសប្បុរសធម៌ ជួយអស់អ្នកត្រូវការខ្លាំង។ កាត់បន្ថយការជិះជាន់ៈ ជំនួសពន្ធលើប្រាក់ចំណូល ជាមួយពន្ធលក់ដូរ។ គោលដៅៈ ជីវិតល្អថ្លៃថ្លាសំរាប់ទាំងអស់គ្នា។

អ៊ីមែល: herb@herbpeters.com
http://www.revival-herbpeters.com

លំដាប់លំដោយនៃសេចក្តីថ្លែង ត្រូវបានសំរេចដោយការចាប់យកអក្ខរក្រមព្រាវៗ។ សេចក្តីថ្លែងនៅទំព័រនេះ បានឧបត្ថម្ភ ដោយបេក្ខជន និងមិនទាន់បានពិនិត្យមើលភាពត្រឹមត្រូវនៅឡើយទេ។ សេចក្តីថ្លែងនិមួយៗ ត្រូវបានបញ្ជូនមកដោយ ស្ម័គ្រចិត្ត និងបានបង់ប្រាក់ដោយបេក្ខជន។ បេក្ខជនដែលមិនបានបញ្ជូនសេចក្តីថ្លែងមក បើមិនដូច្នេះទេ អាចនឹងមាន គុណសម្បត្តិ បង្ហាញនៅលើសន្លឹកឆ្នោត។

# សេចក្តីថ្លែងរបស់បេក្ខជន

## ព្រឹទ្ធសភាសហរដ្ឋអាមេរិក

---



### Tom Palzer | សាធារណរដ្ឋ

ខ្ញុំឈរឈ្មោះសំរាប់ព្រឹទ្ធសភាសហរដ្ឋអាមេរិក ដើម្បីស្តាបនារដ្ឋាភិបាលអភិរក្សឡើងវិញ មករដ្ឋកាលីហ្វ័រនីញ៉ា និងជាតិ។ ខ្ញុំមានបទពិសោធន៍ 32 ឆ្នាំ ឲ្យឱវាទដល់មន្ត្រីជាប់ឆ្នោត នៅគ្រប់ជាន់ថ្នាក់ទាំងអស់នៃរដ្ឋាភិបាល។ ភាពចំបង: ការពារជាតិ, ប្រឆាំងភេរវកម្ម, សេដ្ឋកិច្ច, កិច្ចការអតីតយុទ្ធជន, ជីវិតនៅពេលចាប់កំណើត។


7259 Corvina Ct., Unit 26
Rancho Cucamonga, CA 91739

ទូរស័ព្ទ: (909) 913-9500
អ៊ីមែល: info@us-senateseat2016.com
http://www.us-senateseat2016.com


---



### Greg Conlon | សាធារណរដ្ឋ

ខ្ញុំធ្លាប់ជាដៃគូម្នាក់នៅក្នុងក្រុមហ៊ុនគណនីអន្តរជាតិ បំរើអតិថិជនជា CPA (វិជ្ជាជីវៈគណនេយ្យករ) និងបានធ្វើជាអ្នកប្រឹក្សាពាណិជ្ជកម្មសំរាប់ អង្គភាពពាណិជ្ជកម្មជាច្រើន។ ខ្ញុំមានអាជ្ញាប័ណ្ណជាមេធាវីនៅក្នុងវ៉ាស៊ីងតោនឌីស៊ី និងធ្លាប់ជាអ្នកបើកយន្តហោះ ក្នុងកងទ័ពជើងអាកាសអាមេរិក។ ខ្ញុំយល់ថាសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងឧបសគ្គខាងច្បាប់ ក្នុងតុល្យការគំរោងថវិកា និងបំរើសាធារណជន និងអតីតយុទ្ធជនឲ្យមានប្រសិទ្ធភាព។ លើសពីនេះទៀត ខ្ញុំជា Eagle Scout ម្នាក់។ ឋានៈជាស្នងការ និងប្រធាននៃគណៈកម្មាធិការទឹកភ្លើងសាធារណ រដ្ឋកាលីហ្វ័រនីញ៉ា (California Public Utilities Commission) ខ្ញុំបានទទួលបន្ទុកខាងនីតិវិធីដែលអនុញ្ញាតឲ្យអតិថិជនតាមមូលដ្ឋាន និងពាណិជ្ជកម្ម អាចទិញទឹកភ្លើងផ្ទាល់ពីក្រុមហ៊ុនឯកជន និងអង្គភាពសាធារណៈក្នុងសហគមន៍ មិនមែនទឹកភ្លើងមានម្ចាស់ឯកជន។ ខ្ញុំក៏បានដឹកនាំបណ្តើមគំនិតមួយ ដែលបានបង្កើនការប្រកួតប្រជែង និងបានអនុញ្ញាតឲ្យពាណិជ្ជកម្មជ្រើសរើសក្រុមហ៊ុនទូរគមនាគមន៍ផ្សេងទៀត។ បើសិនខ្ញុំបានជាប់ឆ្នោត ខ្ញុំមានទិសដៅបីយ៉ាង: *ទីមួយ* កាត់បន្ថយទំហំរដ្ឋាភិបាល និងធ្វើឲ្យគំរោងថវិការដ្ឋបាលសហព័ន្ធមានតុល្យភាពជារៀងរាល់ឆ្នាំ តាមការកាត់បន្ថយកំឡាំងគ្រប់គ្រងការងារ ក្នុងភ្នាក់ងាររដ្ឋបាលសហព័ន្ធ និងមិនជំនួសនិយោជិតបានចូលនិវត្តន៍។ *ទីពីរ* ដោះស្រាយបញ្ហាអន្តោប្រវេសន៍ តាមការពង្រឹងព្រំដែនរបស់យើង បង្ខំឲ្យមានអាណត្តិទិដ្ឋាការដបានចេញឲ្យពលរដ្ឋបរទេស និងកាត់បន្ថយការផ្តល់ថវិកានៃរដ្ឋបាលសហព័ន្ធ ទៅឲ្យទីក្រុងហៅថា បដិសរណដ្ឋាន ឬទីជំរក។ *ទីបី* ផ្តល់ការងារឲ្យផ្នែកឯកជន តាមការកាត់បន្ថយកំរិតពន្ធលើប្រាក់ចំណូល ទៅលើពាណិជ្ជកម្មធំ ជា 5% សំរាប់ឲ្យសហរដ្ឋអាមេរិកបានប្រាក់មកវិញ ជាថ្នូរសំរាប់ការបង្កើតការងារថ្មី។ ខ្ញុំធ្លាប់ជាអ្នកឈរឈ្មោះ ឲ្យបក្សសាធារណរដ្ឋ សំរាប់ហេរញ្ញិករដ្ឋ ក្នុងឆ្នាំ 2014 និងបានប្រមូលសន្លឹកឆ្នោតស្ទើរតែ 3.0 លាន; ខ្ញុំដឹងរបៀបធ្វើឲ្យបានជោគជ័យក្នុងការបោះឆ្នោតទូទៅ។ ខ្ញុំទន្ទឹងនឹងធ្វើតំណាងឲ្យរដ្ឋកាលីហ្វ័រនីញ៉ា ហើយនឹងបានកិត្តិយសឲ្យមានឆ្នោតរបស់លោកអ្នក។


3875 Bohannon Dr.
P.O. Box 2600
Menlo Park, CA 94027

ទូរស័ព្ទ: (650) 315-4956
អ៊ីមែល: conlonpg@msn.com
www.gregconlon.com


---


លំដាប់លំដោយនៃសេចក្តីថ្លែង ត្រូវបានសំរេចដោយការចាប់យកអក្ខរក្រមព្រាវៗ។ សេចក្តីថ្លែងនៅទំព័រនេះ បានឧបត្ថម្ភដោយបេក្ខជន និងមិនទាន់បានពិនិត្យមើលភាពត្រឹមត្រូវនៅឡើយទេ។ សេចក្តីថ្លែងនិមួយៗ ត្រូវបានបញ្ជូនមកដោយស្ម័គ្រចិត្ត និងបានបង់ប្រាក់ដោយបេក្ខជន។ បេក្ខជនដែលមិនបានបញ្ជូនសេចក្តីថ្លែងមក បើមិនដូច្នេះទេ អាចនឹងមានគុណសម្បត្តិ បង្ហាញនៅលើសន្លឹកឆ្នោត។

# សេចក្តីថ្លែងរបស់បេក្ខជន

## ព្រឹទ្ធសភាសហរដ្ឋអាមេរិក

### Karen Roseberry | សាធារណរដ្ឋ



*S.A.V.E. អនាគត!*

Palmdale, CA

អ៊ីមែល: karenroseberryforsenate@gmail.com
www.karenroseberryforsenate.com

### Von Hougo | សាធារណរដ្ឋ



“យើងជាប្រជាជន” គឺជាគ្រឹះស្ថាននៃជាតិដ៏អស្ចារ្យនេះ។ ឋានៈជាព្រឹទ្ធសភាសហរដ្ឋអាមេរិក ខ្ញុំនឹងធ្វើការជាមួយក្រុមហ៊ុនបច្ចេកវិជ្ជាដែលមានមូលដ្ឋាននៅរដ្ឋកាលីហ្វ័រនីញ៉ា ដើម្បីបង្កើតគោលនយោបាយ អ្នកបោះឆ្នោតកាច់ចង្កូត ដែលអនុញ្ញាតឲ្យលោកអ្នកបញ្ចេញមតិរបស់លោកអ្នក ទៅលើរាល់គំរោងច្បាប់ នៅមុខព្រឹទ្ធសភា។ គំរោងច្បាប់និមួយៗនឹងបានគូសបញ្ជាក់ ដោយមតិស្រប ជំទាស់ អត្ថប្រយោជន៍ គ្រោះថ្នាក់ និងតម្លៃការវិភាគ។ លោកអ្នកអាចបោះឆ្នោតរបស់លោកអ្នក ហើយលទ្ធផលទូទាំងរដ្ឋ នឹងបានបង្ហាញក្នុងពេលពិតៗ។ ខ្ញុំនឹងបោះឆ្នោតនៅក្នុងព្រឹទ្ធសភា យោទៅលើសំឡេងឆ្នោតភាគច្រើននៃពលរដ្ឋកាលីហ្វ័រនីញ៉ា—រៀងរាល់ពេលទាំងអស់។ យ៉ាងនេះនឹងធ្វើឲ្យប្រាកដ ថាខ្ញុំតែងតែទទួលខុសត្រូវជានិច្ច និងធ្វើការក្នុងផលប្រយោជន៍ល្អបំផុត សំរាប់ប្រជាជននៃរដ្ឋកាលីហ្វ័រនីញ៉ា។ យ៉ាងនេះអះអាងដល់ការបោះឆ្នោត នឹងអាចឲ្យគេបានឮសំឡេងរបស់លោកអ្នក ហើយឆ្នោតរបស់លោកអ្នកបានរាប់នៅលើរាល់គំរោងច្បាប់ មិនមែនគ្រាន់តែខួបបោះឆ្នោតម្តងៗឡើយ។ លោកអ្នកក៏អាចបញ្ជាក់កំរិតការចូលប្រឡូករបស់លោកអ្នក តាមការជ្រើសរើសរឿងរ៉ាវដែលជាសារៈសំខាន់ដល់លោកអ្នក។ នៅពេលណាគំរោងច្បាប់បានមកនៅមុខព្រឹទ្ធសភា លោកអ្នកនឹងបានផ្ញើសារ ឬការជំរាបដំណឹងតាមអ៊ីមែល។ ឆ្នោតរបស់លោកអ្នកនឹងពិតជាសំខាន់។ គោលនយោបាយនេះនឹងធ្វើឲ្យរដ្ឋាភិបាលរបស់យើង ទទួលខុសត្រូវចំពោះប្រជាជននៃរដ្ឋកាលីហ្វ័រនីញ៉ា តាមការជំទាស់ស្ថានភាពដដែលៗ: គណៈបក្សនយោបាយ, PAC, និងចំណង់ពិសេស។ ខ្ញុំនឹងដាក់អំណាចទៅក្នុងកណ្តាប់ដៃរបស់ប្រជាជនវិញ ដែលវាជាកម្មសិទ្ធរបស់ប្រជាជន។ ខ្ញុំទន្ទឹងដើម្បីធ្វើការជាមួយលោកអ្នក សំរាប់រដ្ឋកាលីហ្វ័រនីញ៉ាល្អប្រសើរឡើង។ សំរាប់ព័ត៌មានបន្ថែម ឬដើម្បីយល់ព្រមអំណោយការឃោសនាសេរីរបស់ខ្ញុំ សូមមើល von4senate.org។ សំឡេងរបស់លោកអ្នក។ ឆ្នោតរបស់លោកអ្នក។ ព្រឹទ្ធសភារបស់លោកអ្នក។ សូមបោះឆ្នោតឲ្យ Von Hougo សំរាប់ព្រឹទ្ធសភាសហរដ្ឋអាមេរិក។

27552 Mariam Pl.
Santa Clarita, CA 91350

ទូរស័ព្ទ: (661) 219-3268 (661) 296-3589
អ៊ីមែល: vonhougo@gmail.com
von4senate.com

លំដាប់លំដោយនៃសេចក្តីថ្លែង ត្រូវបានសំរេចដោយការចាប់យកអក្ខរក្រមព្រាវៗ។ សេចក្តីថ្លែងនៅទំព័រនេះ បានឧបត្ថម្ភ ដោយបេក្ខជន និងមិនទាន់បានពិនិត្យមើលភាពត្រឹមត្រូវនៅឡើយទេ។ សេចក្តីថ្លែងនិមួយៗ ត្រូវបានបញ្ជូនមកដោយ ស្ម័គ្រចិត្ត និងបានបង់ប្រាក់ដោយបេក្ខជន។ បេក្ខជនដែលមិនបានបញ្ជូនសេចក្តីថ្លែងមក បើមិនដូច្នេះទេ អាចនឹងមាន គុណសម្បត្តិ បង្ហាញនៅលើសន្លឹកឆ្នោត។

# សេចក្តីថ្លែងរបស់បេក្ខជន

## ព្រឹទ្ធសភាសហរដ្ឋអាមេរិក



### Jason Hanania | គ្មានប្រកាន់គណៈបក្ស

01100101.

182 Howard St. #121
San Francisco, CA 94105

ទូរស័ព្ទ: (415) 654-6291
អ៊ីមែល: 2016@jasonhanania.com
www.jasonhanania.com



### Kamala D. Harris | ប្រជាធិបតេយ្យ

ខ្ញុំឈ្មោះ Kamala Harris។ ខ្ញុំឈរឈ្មោះសំរាប់ព្រឹទ្ធសភាសហរដ្ឋអាមេរិក ពីព្រោះខ្ញុំជឿថាវាដល់ពេលជួសជុលជណ្តើរនៃឱកាសសំរាប់ ពលរដ្ឋកាលីហ្វ័រនីញ៉ាច្រើននាក់ និងប្រជាជនអាមេរិកច្រើននាក់។ ខ្ញុំមានមោទនភាពជាកូនស្រីនៃរដ្ឋកាលីហ្វ័រនីញ៉ា។ ខ្ញុំបានកើតនៅក្នុង Oakland។ ខ្ញុំបានទៅរៀននៅសាលាសាធារណៈរដ្ឋកាលីហ្វ័រនីញ៉ា។ ឋានៈជារដ្ឋអាជ្ញាយូរយារ ខ្ញុំតែងតែបានបំរើអតិថិជនតែមួយៈ ប្រជាជននៃរដ្ឋកាលីហ្វ័រនីញ៉ា។ ឋានៈជាមេធាវីមណ្ឌលនៃ San Francisco និងអគ្គមេធាវីរដ្ឋកាលីហ្វ័រនីញ៉ា ខ្ញុំបានធ្វើអ្វីបានសំរេចសំរាប់ប្រជាជននៃរដ្ឋកាលីហ្វ័រនីញ៉ា។ ខ្ញុំបានចាត់វិធានការទៅលើមនុស្សឃោឃៅ រួមទាំងក្រុមឧក្រិដ្ឋកម្មឆ្លងជាតិ និងពួកជួញដូរមនុស្ស ដែលបានកម្រៃពីការកេងប្រយោជន៍ស្ត្រីភេទ និងក្មេងៗ។ ខ្ញុំក៏បានចាត់វិធានការទៅលើអ្នកធ្វើឲ្យកខ្វក់ធំៗ និងធនាគារធំៗ និងបានធ្វើការឆ្លងជួរបក្ស ដើម្បីអនុម័តច្បាប់ដ៏តឹងបំផុតរបស់ជាតិ ប្រឆាំងនឹងធនាគាររឹបអូសផ្ទះ ដើម្បីការពារម្ចាស់ផ្ទះរបស់យើងរាល់គ្នា។ នេះគឺរបៀបដែលខ្ញុំនឹងនាំមក ឋានៈជាព្រឹទ្ធសភាសហរដ្ឋអាមេរិករបស់លោកអ្នក។ ខ្ញុំនឹងតស៊ូមតិឲ្យមានការងារសំរាប់ប្រជាជនរបស់យើងដែលត្រូវការ តាមការយកប្រាក់មកឲ្យឃ្លាំងរដ្ឋបាលសហព័ន្ធ ដែលនឹងជួសជុលប្រព័ន្ធទឹក និងការដឹកជញ្ជូនរបស់យើងដែលកំពុងតែទ្រុឌទ្រោម។ ខ្ញុំនឹងតស៊ូមតិឲ្យមានសាលារៀនល្អប្រសើរឡើង និងឲ្យក្មេងៗគ្រប់ៗគ្នា អាចចូលរៀននៅបឋមមត្តេយ្យសាលា និងការថែទាំក្មេងដែលអាចផ្គត់ផ្គង់បាន។ ខ្ញុំនឹងតស៊ូមតិសំរាប់អតីតយុទ្ធជនរបស់យើង ដែលគម្បីទទួលគុណភាពការថែទាំសុខភាព និងហ្វឹកហ្វឺនការងារ នៅពេលគេត្រឡប់មកផ្ទះវិញ។ ខ្ញុំនឹងការពារបរិស្ថាន និងឆ្នេរសមុទ្ររបស់យើង និងដឹកនាំការតស៊ូមតិប្រឆាំងនឹងការផ្លាស់ប្តូរអាកាសធាតុ។ ហើយឋានៈជាអាជីវកររដ្ឋអាជ្ញាម្នាក់ ខ្ញុំនឹងធ្វើការរាល់ថ្ងៃ ដើម្បីរក្សាប្រជាជនរបស់យើងឲ្យបានសុខពីភេរវកម្ម ទាំងនៅក្នុងមាតុភូមិ និងបរទេស។ សូមចូលរួមជាមួយខ្ញុំ។ សូមអរគុណចំពោះការពិចារណារបស់លោកអ្នក។

P.O. Box 78393
San Francisco, CA 94107

ទូរស័ព្ទ: (213) 221-1269
អ៊ីមែល: info@kamalaharris.org
www.kamalaharris.org

លំដាប់លំដោយនៃសេចក្តីថ្លែង ត្រូវបានសំរេចដោយការចាប់យកអក្ខរក្រមព្រាវៗ។ សេចក្តីថ្លែងនៅទំព័រនេះ បានឧបត្ថម្ភដោយបេក្ខជន និងមិនទាន់បានពិនិត្យមើលភាពត្រឹមត្រូវនៅឡើយទេ។
សេចក្តីថ្លែងនិមួយៗ ត្រូវបានបញ្ជូនមកដោយស្ម័គ្រចិត្ត និងបានបង់ប្រាក់ដោយបេក្ខជន។ បេក្ខជនដែលមិនបានបញ្ជូនសេចក្តីថ្លែងមក បើមិនដូច្នេះទេ អាចនឹងមានគុណសម្បត្តិ បង្ហាញនៅលើសន្លឹកឆ្នោត។

# សេចក្តីថ្លែងរបស់បេក្ខជន

## ព្រឹទ្ធសភាសហរដ្ឋអាមេរិក



### Mike Beitiks | គ្មានប្រកាន់គណៈបក្ស

គោលនយោបាយរបស់ខ្ញុំមានព្រំដែន។ វាពិតជាគណៈកម្មាការតែមួយ។ នីតិបុគ្គលរដ្ឋបាលសហព័ន្ធ មិនធ្វើអ្វីសោះដើម្បីការពារយងពីការគំរាមកំហែងនៃការផ្លាស់ប្តូរអាកាសធាតុឡើយ។ ខ្ញុំនឹងមិនធ្វើអ្វីទេ។ ខ្ញុំស្បថទៅលើផ្ទួរអនាគតនៃពលរដ្ឋកាលីហ្វ័រនីញ៉ាថាខ្ញុំនឹងមិនពលីកម្មដល់អាកាសធាតុពិតរបស់យើង ចំពោះនយោបាយអាកាសធាតុរបស់យើងឡើយ។

www.Iwillnotdonothing.org



### Jason Kraus | គ្មានប្រកាន់គណៈបក្ស

ការបោះឆ្នោតម្តងៗ ធ្វើឲ្យពលរដ្ឋកាលីហ្វ័រនីញ៉ាបានផ្ទុកដោយបញ្ហាដដែលៗ រឿងរ៉ាវដដែលៗ និងមុខដដែលៗ។ អ្នកនយោបាយអង្វរសុំប្រាក់របស់យើង ដោយធ្វើការសន្យាដែលនឹងមិនរក្សាទុកឡើយ។ យើងត្រូវតែបកទៅមូលដ្ឋានវិញ។ យកទំរង់ពន្ធលើប្រាក់ចំណូលទាំងអស់ចេញ ដែលនឹងបង្កើនការងារ បញ្ឆេះសេដ្ឋកិច្ចរបស់យើង និងការពារដំណើរជីវិតរបស់យើង។ ខ្ញុំបានបដិសេធការបរិច្ចាគឃោសនាទាំងអស់ ទាំងនឹងមិនទទួលយកប្រាក់ខែ ហើយនឹងបំរើតែមួយអាណត្តិប៉ុណ្ណោះ។ ខ្ញុំមិនមែនជាបក្សសាធារណរដ្ឋ ឬបក្សប្រជាធិបតេយ្យឡើយ។ ខ្ញុំជាប្រជាជនអាមេរិកម្នាក់ . . . ដូចជាលោកអ្នកដែរ។ សូមបោះឆ្នោតឲ្យ Jason Kraus។ សំរាប់ព្រឹទ្ធសភាសហរដ្ឋអាមេរិកឆ្នាំ 2017។ សំរាប់ព័ត៌មានបន្ថែម សូមមើល *www.aleadernotapolitician.com*។

ទូរស័ព្ទ: (916) 542-8721
អ៊ីមែល: Jason@ALeaderNotAPolitician.com
www.aleadernotapolitician.com

លំដាប់លំដោយនៃសេចក្តីថ្លែង ត្រូវបានសំរេចដោយការចាប់យកអក្ខរក្រមព្រាវៗ។ សេចក្តីថ្លែងនៅទំព័រនេះ បានឧបត្ថម្ភ ដោយបេក្ខជន និងមិនទាន់បានពិនិត្យមើលភាពត្រឹមត្រូវនៅឡើយទេ។
សេចក្តីថ្លែងនិមួយៗ ត្រូវបានបញ្ជូនមកដោយ ស្ម័គ្រចិត្ត និងបានបង់ប្រាក់ដោយបេក្ខជន។ បេក្ខជនដែលមិនបានបញ្ជូនសេចក្តីថ្លែងមក បើមិនដូច្នេះទេ អាចនឹងមាន គុណសម្បត្តិ បង្ហាញនៅលើសន្លឹកឆ្នោត។

# សេចក្តីថ្លែងរបស់បេក្ខជន

## ព្រឹទ្ធសភាសហរដ្ឋអាមេរិក



**Don Krampe** | សាធារណរដ្ឋ

ឋានៈជាទ័ពជើងទឹកសហរដ្ឋអាមេរិកម្នាក់ ខ្ញុំបានបំរើប្រទេសរបស់ខ្ញុំក្នុងសមរភូមិ ក្នុងអំឡុងពេលសង្គ្រាមកូរ៉េ។ ក្រោយមកខ្ញុំក៏បានបំរើអតីតយុទ្ធជនជាតិរបស់យើង ឋានៈជានាយក USO ក្នុងប្រទសវៀតណាម និងជាអ្នកជំនួយដល់នាយកភូមិភាគ សំរាប់នាយកដ្ឋានអតីតយុទ្ធជន។ នៅឆ្នាំ 1958 ខ្ញុំបានរួមរកឃើញនូវ សិក្ខាសាលាភាពដឹកនាំកំឡោះក្រមុំ Hugh O'Brian (Hugh O'Brian Young Adult Leadership Seminars) ដែលចាប់តាំងពីការកកើតរបស់វាមក វាបានផ្តល់អត្ថប្រយោជន៍ឲ្យក្មេងប្រុសៗ និង ក្មេងស្រីៗរាប់ពាន់នាក់។ ខ្ញុំបានសញ្ញាប័ត្រ បរិញ្ញាទោនៃសាធារណៈការគ្រប់គ្រង មកពីសាកលវិទ្យាល័យ Cal Lutheran។ ខ្ញុំជឿថាប្រព័ន្ធពីរគណៈបក្សរបស់យើង គឺមិនដំណើរការ និងមិនយល់ន័យសង្ខេប "'TEAM'—គ្រប់ៗគ្នាទាំងអស់គ្នាសំរេចបំណងច្រើន" (TEAM—Together Everyone Achieves More) ឡើយ។ ធនធានដ៏ធំធេងនៃប្រទេសរបស់យើង គឺកំឡោះក្រមុំ និងសិស្សានុសិស្សដែលត្រូវតែបានបង្រៀន "មិនមែនអ្វីត្រូវគិតគូរទេ ប៉ុន្តែពីរបៀបគិតគូរវិញ"។ ត្បិតជំនឿអាមេរិកប្រកបដោយវចីកោសល្យថ្លែងថា: "ខ្ញុំជឿក្នុងសហរដ្ឋអាមេរិក ជារដ្ឋាភិបាលរបស់ប្រជាជន ដោយប្រជាជន សំរាប់ប្រជាជន; ដែលអំណាចរបស់គេបានមកពីការ យល់ព្រមដែលបានគ្រប់គ្រង ជាលទ្ធិប្រជាធិបតេយ្យក្នុងអធិបតេយ្យជាតិសាធារណរដ្ឋ នៃរដ្ឋអធិបតេយ្យជាច្រើន; សហភាពដ៏ឥត ខ្ចោះមួយ និងមិនអាចបំបែកបាន: បានស្ថាបនាទៅលើគោលការណ៍នៃសេរីភាព សមភាព យុត្តិធម៌ និងមនុស្សធម៌ សំរាប់អ្នកស្នេហាជាតិអាមេរិកដែលបានបូរជាជីវិត និងទ្រព្យសម្បត្តិរបស់គេ។ ដោយសារហេតុនេះ ខ្ញុំជឿថាវាជាភារៈកិច្ចរបស់ខ្ញុំ ចំពោះប្រទេសរបស់ខ្ញុំ ដើម្បីស្រឡាញ់វា គាំទ្ររដ្ឋធម្មនុញ្ញរបស់វា គោរពច្បាប់របស់វា និងដើម្បីគោរពទង់ជាតិរបស់វា និងដើម្បីការពារវា ប្រឆាំងនឹងសត្រូវ ទាំងអស់។ ខ្ញុំសូមថ្លែងអំណរគុណចំពោះការពិចារណារបស់លោកអ្នក។ ដើម្បីឲ្យបានដឹងថែមទៀត សូមមើលវ៉ិបសៃត៍របស់ខ្ញុំនៅ: *2016krampeforsenate.com*។

40581 Via Amapola
Murrieta, CA 92562

ទូរស័ព្ទ: (951) 600-0542
អ៊ីមែល: xptriumph@hotmail.com
www.2016krampeforsenate.com

លំដាប់លំដោយនៃសេចក្តីថ្លែង ត្រូវបានសំរេចដោយការចាប់យកអក្ខរក្រមព្រាវៗ។ សេចក្តីថ្លែងនៅទំព័រនេះ បានឧបត្ថម្ភដោយបេក្ខជន និងមិនទាន់បានពិនិត្យមើលភាពត្រឹមត្រូវនៅឡើយទេ។ សេចក្តីថ្លែងនិមួយៗ ត្រូវបានបញ្ជូនមកដោយស្ម័គ្រចិត្ត និងបានបង់ប្រាក់ដោយបេក្ខជន។ បេក្ខជនដែលមិនបានបញ្ជូនសេចក្តីថ្លែងមក បើមិនដូច្នេះទេ អាចនឹងមានគុណសម្បត្តិ បង្ហាញនៅលើសន្លឹកឆ្នោត។